ស្ថិតិយេនឌ័រ ខេត្តកំពង់ឆ្នាំង

គម្រោងបញ្ជ្រាបយេនឌ័រ
ដើម្បីបង្កើនតារាងអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី (PGM-WEE)
ខែឧសភា ឆ្នាំ ២០២១

Project On Gender Mainstreaming For
Women's Economic Empowerment (PGM-WEE)
May, 2021

Gender Statistics
Kampong Chhnang Province

អារម្ភកថា

ក្រសួងកិច្ចការនារី គឺជាយន្តការជាតិសម្រាប់លើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី ។ ក្រសួងកិច្ចការនារី ដើរតួនាទីជាអ្នកជំរុញ ស្វែងរកការគាំទ្រមតិ ទំនាក់ទំនង និងសម្របសម្រួល ដើម្បីលើកទឹកចិត្តឲ្យស្ថាប័នរដ្ឋ សង្គមស៊ីវិល និងផ្នែកឯកជន ធ្វើការបញ្ចូលទស្សនៈយេនឌ័រក្នុងគោលនយោបាយ និងកម្មវិធីរបស់ខ្លួន។ ស្ថានភាពបែបនេះ ក្រសួងកិច្ចការនារី បានរៀបចំផែនការនារីរតនៈ ដែលជាយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំ (២០១៩-២០២៣) សម្រាប់លើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រីនៅកម្ពុជា។

គម្រោង«បញ្ជាបយេនឌ័រដើម្បីបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី (PGM- WEE)» ត្រូវបានចាប់ផ្តើមអនុវត្តចាប់តាំងពីខែមីនា ឆ្នាំ២០១៧ ក្រោមការឧបត្ថម្ភគាំទ្រពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) ។ គម្រោងនេះមានគោលបំណង ពង្រឹងការបញ្ជាបយេនឌ័រ និងលើកកម្ពស់ការអនុវត្តសកម្មភាពផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីឱ្យមាន តាមរយៈការស្វែងរកការគាំទ្រមតិ សម្របសម្រួលដោយក្រសួងកិច្ចការនារី មន្ទីរកិច្ចការនារី ក្រសួង និងមន្ទីរពាក់ព័ន្ធ។

ស្ថិតិយេនឌ័រ គឺជាផ្នែកមួយនៅក្នុងសកម្មភាពរបស់គម្រោង។ ការបង្កើតសៀវភៅស្ថិតិយេនឌ័រ នៅក្នុងខេត្តកំពង់ឆ្នាំងគឺ ជាសមាសធាតុដ៏សំខាន់មួយដែលចងក្រងឡើងដោយមន្ទីរពាក់ព័ន្ធដែលជាសមាជិកក្រុមការងារបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី(WEE) និងមន្ទីរអង្គភាពពាក់ព័ន្ធជុំវិញខេត្ត/កំពង់ឆ្នាំង សម្របសម្រួលដោយក្រសួងកិច្ចការនារី និងមានការគាំទ្របច្ចេកទេសពីក្រុមការងាររបស់គម្រោង។

ទិន្នន័យ និងព័ត៌មានទាំងអស់នៅក្នុងសៀវភៅស្ថិតិនេះ បង្ហាញអំពីស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ច ក៏ដូចជាផ្តល់ភាពអង់អាចដល់ស្ត្រីនៅក្នុងខេត្តកំពង់ឆ្នាំង។ ដូច្នេះខ្ញុំជឿជាក់ថា សៀវភៅនេះ គ្រប់ស្ថាប័នពាក់ព័ន្ធទាំងអស់ នឹងយកទៅប្រើប្រាស់ សម្រាប់ធ្វើការតាមដានត្រួតពិនិត្យ គោលនយោបាយ ផែនការ និងកម្មវិធី ឆ្លើយតបនឹងយេនឌ័រតាមវិស័យនីមួយៗ។

ជ.រដ្ឋមន្ត្រី
រដ្ឋលេខាធិការ

ច័ន្ទ សូរីយ៍

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តកំពង់ឆ្នាំង
លេខ:.៥១២/២១ សរ-ស

ថ្ងៃសុក្រ ៣ កើត ខែ ចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
កំពង់ឆ្នាំង,ថ្ងៃទី៣០ខែមីនាឆ្នាំ ២០២១

សេចក្តីថ្លែងអំណរគុណ

ដោយមានការជួយឧបត្ថម្ភគាំទ្រផ្នែកបច្ចេកទេស និងថវិកាពីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) ក្នុងកិច្ចសហការជាមួយក្រសួងកិច្ចការនារី បានរៀបចំសៀវភៅស្ថិតិយេនឌ័រ នៅខេត្តកំពង់ឆ្នាំង ។ សៀវភៅស្ថិតិយេនឌ័រនេះនឹងយកទៅប្រើប្រាស់សម្រាប់ រដ្ឋបាលខេត្តកំពង់ឆ្នាំង ដៃគូអភិវឌ្ឍន៍ជាតិ អន្តរជាតិ និងអ្នកពាក់ព័ន្ធនានា ដើម្បីដាក់បញ្ចូលទស្សនៈយេនឌ័រទៅក្នុងគោលនយោបាយ ផែនការ និងកម្មវិធីនានា ជាពិសេសបានរួមចំណែកក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងបរិយាប័ន្ន ។

រដ្ឋបាលខេត្តកំពង់ឆ្នាំងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការខិតខំប្រឹងប្រែងរបស់ **លោកជំទាវ កិត្តិបណ្ឌិត អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី** ដែលតែងតែគាំទ្រ និងផ្តល់ឱកាសឱ្យមន្ត្រីដៃគូ ធ្វើការរួមគ្នាជាមួយសមាជិកក្រុមការងារបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ខេត្តកំពង់ឆ្នាំង ក្នុងការចងក្រង និងបង្កើតសៀវភៅស្ថិតិនេះឡើង។

រដ្ឋបាលខេត្តកំពង់ឆ្នាំងសង្ឃឹមថា សៀវភៅនេះនឹងផ្តល់ប្រយោជន៍សម្រាប់ថ្នាក់ដឹកនាំ មន្ត្រីរាជការខេត្តកំពង់ឆ្នាំង និងមន្ទីរពាក់ព័ន្ធយកទៅប្រើប្រាស់សម្រាប់ការអនុវត្តគម្រោងនានាផងដែរ។ លើសពីនេះទៅទៀតនឹងត្រូវបានប្រើប្រាស់សម្រាប់ធ្វើការត្រួតពិនិត្យ តាមដាននូវគោលនយោបាយ និងផែនការឆ្លើយតបទៅនឹងយេនឌ័រ ដើម្បីធានាបាននូវប្រសិទ្ធភាព និងប្រសិទ្ធផលនៃការផ្តល់សេវា សាធារណៈ រួមទាំងការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី។

អភិបាលខេត្ត

ឈួរ ចន្ទឿន

មាតិកា

ប្រវត្តិសង្ខេប v

ផែនទីខេត្ត vi

១.ស្ថានភាពទូទៅខេត្តកំពង់ឆ្នាំង 1

១.១.ទីតាំងភូមិសាស្ត្រ 1

១.២. ចំនួនប្រជាជន 2

ក្រាហ្វិក ១៖ អត្រាកំណើនប្រជាជនប្រចាំឆ្នាំ 2

ក្រាហ្វិក ២៖ ចំនួនប្រជាជនបែងចែកតាមក្រុង/ស្រុកក្នុងឆ្នាំ២០១៩ 2

ក្រាហ្វិក ៣៖ ភាគរយស្ត្រី និងបុរសជាមេគ្រួសារបែងចែកតាមក្រុង/ស្រុកក្នុងឆ្នាំ២០១៩ 3

១.៣. ស្ថានភាពភាពក្រីក្រ 3

ក្រាហ្វិក ៤៖ អត្រាភាពក្រីក្រ នៅក្នុងខេត្តកំពង់ឆ្នាំងបែងចែកតាមឆ្នាំ 3

តារាងទី១៖ គ្រួសារក្រីក្រ នៃការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រឆ្នាំ២០១៩ 4

១.៤. អតិវឌ្ឍន៍ជនបទ 4

តារាងទី២៖ សូចនាករ និងចំណុចដៅនៃវិស័យអភិវឌ្ឍន៍ជនបទក្នុងឆ្នាំ២០១៩ 4

ក្រាហ្វិក ៥៖ ភាគរយគ្រួសារទទួលទានទឹកស្អាត បែងចែកតាមក្រុង/ស្រុកក្នុងឆ្នាំ២០១៩ 5

តារាងទី៣៖ ស្ថានភាពផ្ទះ និងការប្រើប្រាស់ថាមពលបំភ្លឺក្នុងឆ្នាំ២០១៩ 5

ក្រាហ្វិក ៦៖ ភាគរយផ្ទះមានបណ្តាញអគ្គិសនីប្រើប្រាស់ក្នុងឆ្នាំ២០១៩ 6

២. ផ្នែកសេដ្ឋកិច្ច 6

២.១. ស្ថានភាពទូទៅរបស់ទិស័យឧស្សាហកម្ម 7

តារាងទី៤៖ រោងចក្រ/សហគ្រាសធុនធំ របស់ខេត្ត 7

តារាងទី៥៖ តារាងសិប្បកម្មនៅក្នុងខេត្ត 7

២.២. ចំនួនប្រជាជន និងមុខរបរ 8

តារាងទី៦៖ ស្ថានភាពមុខរបរចម្បងរបស់ប្រជាជន 8

កាប្រ្ទិក ៧៖ ភាគរយប្រជាជន ដែលមានអាយុពី១៨-៦០ឆ្នាំ បែងចែកតាមមុខរបរចម្បង និងតាមភេទក្នុងឆ្នាំ ២០១៩ 9

ក្រាហ្វិក ៨៖ ប្រជាជនដែលមានអាយុពី១៨ឆ្នាំឡើង ធ្វើការងារក្នុងវិស័យកសិកម្ម (មុខរបរចម្បង) បែងចែកតាមភេទ និងក្រុង/ស្រុកក្នុងឆ្នាំ២០១៩ 9

ក្រាហ្វិក ៩៖ ប្រជាជនដែលមានអាយុពី១៨ឆ្នាំឡើង ធ្វើការក្នុងវិស័យឧស្សាហកម្ម និងសិប្បកម្ម (មុខរបរចម្បង) បែងចែកតាមភេទ និងក្រុង/ស្រុកក្នុងឆ្នាំ២០១៩ 10

ក្រាហ្វិក ១០៖ ប្រជាជនមានអាយុ១៨ឆ្នាំឡើង ធ្វើការក្នុងផ្នែកសេវាកម្ម (មុខរបរចម្បង) បែងចែកតាមភេទ និង ក្រុង/ស្រុក ក្នុងឆ្នាំ២០១៩ 10

ក្រាហ្វិក ១១៖ ប្រាក់ខែអប្បបរមារបស់កម្មករនិយោជិត 11

២.៣. ចំណាកស្រុក 11
តារាងទី៧៖ អត្រាចំណាកស្រុក 11
ក្រាហ្វិក ១២៖ ចំនួនស្ត្រី និងបុរសអាយុ១៨ឆ្នាំឡើង ដែលធ្វើចំណាកស្រុកក្នុងប្រទេស ក្នុងឆ្នាំ២០១៩ 12
ក្រាហ្វិក ១៣៖ ចំនួនស្ត្រី និងបុរស អាយុ១៨ឆ្នាំឡើង ដែលធ្វើចំណាកស្រុកទៅក្រៅប្រទេស ក្នុងឆ្នាំ២០១៩ 12
៣. ផ្នែកអប់រំ 13
៣.១. អត្រាចូលរៀនសាលា 13
តារាងទី៨៖ ផ្នែកមត្តេយ្យសិក្សា 13
ក្រាហ្វិក ១៤៖ ចំនួនសិស្សនៅថ្នាក់មត្តេយ្យសិក្សា (រដ្ឋ សហគមន៍ និងឯកជន) 14
ក្រាហ្វិក ១៥៖ ភាគរយកុមារអាយុ៥ឆ្នាំបានចូលរៀនថ្នាក់មត្តេយ្យសិក្សា (រដ្ឋ សហគមន៍ និងឯកជន) បែងចែកតាមក្រុង/ស្រុកក្នុងឆ្នាំសិក្សា២០១៩-២០២០ 15
៣.២. អត្រាចូលរៀនបឋមសិក្សា 15
តារាងទី៩៖ ផ្នែកបឋមសិក្សា 15
ក្រាហ្វិក ១៦៖ ចំនួនសិស្សនៅកម្រិតបឋមសិក្សា (សាលារដ្ឋ) 16
ក្រាហ្វិក ១៧៖ អត្រារួមនៃការសិក្សានៅបឋមសិក្សាបែងចែកតាមក្រុង/ស្រុក ឆ្នាំសិក្សា២០១៩-២០២០ 16
ក្រាហ្វិក ១៨៖ អត្រាសិស្សបោះបង់ការសិក្សានៅបឋមសិក្សា បែងចែកតាមក្រុង/ស្រុកក្នុងឆ្នាំសិក្សា២០១៩-២០២០ 17
ក្រាហ្វិក ១៩៖ អត្រាសិស្សបឋមសិក្សារៀនត្រួតថ្នាក់ បែងចែកតាមភេទ និងក្រុង/ស្រុកក្នុងឆ្នាំសិក្សា 17
២០១៩-២០២០ 17
ក្រាហ្វិក ២០៖ ចំនួនក្មេងប្រុស និងក្មេងស្រី ដែលមិនបានចុះឈ្មោះចូលរៀន អាយុ៦-១១ឆ្នាំ បែងចែងតាមភេទនិងក្រុង/ស្រុកឆ្នាំ២០១៩ 18
៣.៣. អត្រាចូលរៀនមធ្យមសិក្សា 18
តារាងទី១០៖ ផ្នែកមធ្យមសិក្សាបឋមភូមិ 18
ក្រាហ្វិក ២១៖ ចំនួនសិស្សក្នុងកម្រិតមធ្យមសិក្សាបឋមភូមិ 19
ក្រាហ្វិក ២២៖ ចំនួនសិស្សនៅក្នុងកម្រិតមធ្យមសិក្សាបឋមភូមិបែងចែកតាមភេទ និងក្រុង/ស្រុក (ឆ្នាំសិក្សា២០១៩-២០២០) 19
៣.៤. អត្រាចូលរៀនមធ្យមសិក្សាទុតិយភូមិ 20
តារាងទី១១៖ ផ្នែកមធ្យមសិក្សាទុតិយភូមិ 20
ក្រាហ្វិក ២៣៖ ចំនួនសិស្សនៅក្នុងកម្រិតមធ្យមសិក្សាទុតិយភូមិ 20
ក្រាហ្វិក ២៤៖ ចំនួនសិស្ស នៅក្នុងកម្រិតមធ្យមសិក្សាទុតិយភូមិបែងចែកតាមភេទ និងក្រុង/ស្រុក 21
(ឆ្នាំសិក្សា២០១៩-២០២០) 21
៣.៥ អត្រាចូលរៀនឧត្តមសិក្សា 21

ក្រាហ្វិក ២៥៖ ចំនួននិស្សិតនៅក្នុងថ្នាក់មហាវិទ្យាល័យបែងចែកតាមភេទ និងឆ្នាំ 21
តារាងទី១២៖ ផ្នែកអប់រំក្រៅប្រព័ន្ធ 22
៣.៦. ថ្នាក់បំពេញវិជ្ជា 22
តារាងទី១៣៖ ការងារបំពេញវិជ្ជា 22
៣.៧. កម្មវិធីអក្ខរកម្ម 22
តារាងទី១៤៖ ចំនួនថ្នាក់ និងសិស្សចូលរៀនក្នុងកម្មវិធីអក្ខរកម្ម (២០១៩) 23
តារាងទី១៥៖ ចំនួន និងកម្រិតវប្បធម៌របស់គ្រូអក្ខរកម្ម (២០១៩) 23
តារាងទី១៦៖ ចំនួនអ្នកចូលរួម និងជំនាញមុខរបរនីមួយៗក្នុងកម្មវិធីបង្កើនប្រាក់ចំណូល (២០១៩) 24
តារាងទី១៧៖ ចំនួនគ្រូបង្រៀនក្នុងមជ្ឈមណ្ឌលសិក្សាសហគមន៍ក្នុងកម្មវិធីបង្កើនប្រាក់ចំណូល (២០១៩) 24
តារាងទី១៨៖ ចំនួនថ្នាក់ និងអ្នកចូលរួមក្នុងកម្មវិធីបង្កើនប្រាក់ចំណូល បែងចែកតាមស្រុក 25
៣.៩. ផ្សេងៗ 25
តារាងទី១៩៖ ផ្នែកកុមារ និងយុវជន 25
តារាងទី២០៖ ផ្នែកអប់រំកាយ និងកីឡា 25
៤. សុខាភិបាល 26
តារាងទី២១៖ វឌ្ឍនភាពសូចនាករ និងចំនុចដៅសំខាន់ៗនៃវិស័យសុខាភិបាល 26
តារាងទី២២៖ ស្ថានភាពសុខភាពស្ត្រី និងកុមារ 26
ក្រាហ្វិក ២៦៖ ផលធៀបទារកបានកើតក្នុងស្ត្រី ១.០០០នាក់ដែលមានអាយុពី១៥-៤៥ឆ្នាំ 27
តារាងទី២៣៖ ស្ថានភាពគ្រួសារកើតជម្ងឺអេដស៍ 27
ក្រាហ្វិក ២៧៖ ផលធៀបចំនួនគ្រួសារមានសមាជិកកើតជម្ងឺអេដស៍ក្នុង ១.០០០គ្រួសារ 28
៥. ការគ្រប់គ្រងរដ្ឋបាល និងការចូលរួមរបស់ស្ត្រី 28
៥.១. ការចូលរួមរបស់ស្ត្រីក្នុងវិស័យសាធារណៈ 28
តារាងទី២៤៖ គណៈអភិបាលខេត្ត 28
តារាងទី២៥៖ មន្ត្រីរាជការស៊ីវិល 29
តារាងទី២៦៖ ក្រុមប្រឹក្សាខេត្ត 29
តារាងទី២៧៖ គណៈអភិបាលក្រុង/ស្រុក 30
តារាងទី២៨៖ ក្រុមប្រឹក្សាក្រុង/ស្រុក 30
តារាងទី២៩៖ ក្រុមប្រឹក្សាឃុំ/សង្កាត់ 30
តារាងទី៣០៖ រដ្ឋបាលឃុំ/សង្កាត់ និងភូមិ 31
ក្រាហ្វិក ២៨៖ ភាគរយការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេច (២០២០) 32
៥.២. សន្តិសុខ 33
តារាងទី៣២៖ ភាពរងគ្រោះរបស់ស្ត្រីដោយអំពើរំលោភបំពានផ្សេងៗ 33

តារាងទី៣៣៖ អំពើហិង្សាក្នុងគ្រួសារ 33
ក្រាហ្វិក ២៩៖ ផលធៀបចំនួនគ្រួសារមានអំពើហិង្សាក្នុង១.០០០គ្រួសារ ក្នុងឆ្នាំ២០១៩ 34
ក្រាហ្វិក ៣០៖ ផលធៀបករណីអំពើហិង្សាក្នុងគ្រួសារពាក់ព័ន្ធដល់អាជ្ញាធរ (ការអន្តរាគមន៍ពីអាជ្ញាធរ) ក្នុង ១.០០០គ្រួសារ 34

ប្រវត្តិសង្ខេប

ក្រសួងកិច្ចការនារី និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន(JICA) មានប្រវត្តិយូរអង្វែងក្នុងកិច្ចសហការគ្នាចាប់តាំងពីដើមទសវត្សរ៍ទី៩០។ ចាប់តាំងពីឆ្នាំ២០០៣ គម្រោងសហប្រតិបត្តិការបច្ចេកទេសចំនួន០២ ដើម្បីពង្រឹងយន្តការបញ្ជ្រាបយេនឌ័រនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវបានអនុវត្តអស់រយៈពេល ១០ឆ្នាំ ។

គម្រោងស្តីពីការបញ្ជ្រាបយេនឌ័រដើម្បីបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី (PGM-WEE) ត្រូវបានអនុវត្តចាប់តាំងពីខែមីនាឆ្នាំ២០១៧ ដែលមានគោលបំណងដើម្បីលើកកម្ពស់ការអនុវត្តសកម្មភាពបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីប្រកបដោយប្រសិទ្ធភាព ដោយមានក្រសួង/មន្ទីរពាក់ព័ន្ធជាដៃគូ ក្រោមការសម្របសម្រួលរបស់ក្រសួងកិច្ចការនារីតាមរយៈការពង្រឹងយន្តការបញ្ជ្រាបយេនឌ័រ ។

ការផលិត និងចងក្រងស្ថិតិយេនឌ័រនៅថ្នាក់ក្រោមជាតិជាផ្នែកមួយនៃសកម្មភាពរបស់គម្រោង PGM-WEE។

មន្ទីរពាក់ព័ន្ធដែលជាសមាជិកក្រុមការងារ WEE បានប្រមូលទិន្នន័យ និងព័ត៌មានសំខាន់ៗដែលទាក់ទងនឹងស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ចបច្ចុប្បន្នភាពរបស់ស្ត្រី និងបុរសនៅក្នុងខេត្តកំពង់ឆ្នាំង ។ ទិន្នន័យ និងព័ត៌មានទាំងនេះប្រមូលបានពីប្រភពដែលមានស្រាប់ ដូចជាទិន្នន័យមូលដ្ឋាន ឃុំ/សង្កាត់ ខែធ្នូ ឆ្នាំ២០១៩ (ធ្វើបច្ចុប្បន្នភាព) ព័ត៌មាននានាពីមន្ទីរពាក់ព័ន្ធ ព្រមទាំងការិយាល័យតាមស្រុកនានា។ បន្ទាប់មកក្រុមការងារ WEE ធ្វើការពិនិត្យ និងវិភាគលើទិន្នន័យទាំងនោះ និងណែនាំអោយមានការកែសម្រួល និងធ្វើបច្ចុប្បន្នភាពឡើងវិញ។ ហើយបន្ទាប់មក សៀវភៅស្ថិតិយេនឌ័រត្រូវបានបោះពុម្ព និងផ្សព្វផ្សាយជាផ្លូវការនៅក្នុងខេត្ត និងស្ថាប័នពាក់ព័ន្ធដទៃទៀត។

សៀវភៅស្ថិតិយេនឌ័រនេះ នឹងក្លាយជាឯកសារយោងដ៏មានប្រយោជន៍ ក្នុងអំឡុងពេលអនុវត្តគម្រោងសាកល្បង ហើយនឹងត្រូវប្រើប្រាស់ដោយមន្ត្រីថ្នាក់ខេត្ត និងភាគីពាក់ព័ន្ធនានា សម្រាប់រៀបចំគោលនយោបាយ កម្មវិធី និងគម្រោងនានារបស់ខ្លួន។

ផែនទីខេត្ត


ផែនទីរដ្ឋបាល និងហេដ្ឋារចនាសម្ព័ន្ធ ខេត្តកំពង់ឆ្នាំង
Administration and Infrastructure of Kampong Chhang Province
Province Office
District Office
Commune Office
Village
Health Center
Hospital
Pagoda
School
Church
Post Office
Historical Site
Provincial Boundary
District Boundary
Commune Boundary
Sealed Road
Laterite Road
Unsealed Road
Track
Street
Railway
Permanent River
Seasonal Stream
Canal
Major Canal
Dam
Levees
Aural, Wildlife Sanctuary
Tonle Sap, Multiple Use
Built-up area
Village
Kilometers

១.ស្ថានភាពទូទៅខេត្តកំពង់ឆ្នាំង

១.១.ទីតាំងភូមិសាស្ត្រ

ខេត្តកំពង់ឆ្នាំង ជាខេត្តមួយស្ថិតនៅផ្នែកកណ្តាលនៃផ្ទៃប្រទេសក្នុងចំណោមរាជធានី ខេត្តទាំង២៥ នៃព្រះរាជាណាចក្រកម្ពុជាដែលមានព្រំប្រទល់៖ ខាងកើតជាប់ខេត្តកំពង់ចាម ខាងត្បូងជាប់ខេត្តកំពង់ស្ពឺនិងខេត្តកណ្តាល ខាងលិចជាប់ខេត្តពោធិ៍សាត់ និងខាងជើងជាប់ខេត្តកំពង់ធំ។ ខេត្តកំពង់ឆ្នាំងមានផ្ទៃដីសរុប ៥៥២.១០០ ហ.ត ដែលចែកចេញជា៨ក្រុង/ស្រុក ៧០ ឃុំ សង្កាត់ និង ៥៦៩ ភូមិ។

ខេត្តកំពង់ឆ្នាំងនៅជាប់បឹងទន្លេសាប មានធាតុអាកាសប្រែប្រួលតាមរដូវកាល មានភ្លៀងធ្លាក់ចាប់ពីខែមេសាដល់ដើមខែវិច្ឆិកា ធ្វើឲ្យប្រភពទឹកទន្លេសាបមានចរន្តទឹកហូរចេញចូលប្រែប្រួលតាមរដូវកាល និងមានស្ទឹងសំខាន់ៗបួន៖ (១)ស្ទឹងគ្រាំងពន្លៃមានប្រវែង ៦៧គ.ម មានប្រភពពីជួរភ្នំវែងខេត្តកំពង់ស្ពឺ (២)ស្ទឹងជ្រៃបាក់មានប្រវែង ៥៣គ.ម មានប្រភពពីភ្នំឃ្លែងខ្លាជួរភ្នំក្រវ៉ាញ (៣)ស្ទឹងសាបអង្កាម និង (៤)ស្ទឹងបរិបូណ៌ាមានប្រវែង ៦៦,៥០គ.ម មានប្រភពពីជួរភ្នំក្រវ៉ាញដែលជាប្រព័ន្ធបង្ហូរទឹកធម្មជាតិបែងចែក ជាព្រែកអូរ និងប្រឡាយតូចៗជាច្រើនចែកទៅតាមតំបន់ដី បង្កបង្កើនផលដំណាំស្រូវ ដំណាំរួមផ្សំផ្សេងៗ និង ដំណាំកសិ-ឧស្សាហកម្ម ព្រមទាំងមានលទ្ធភាពបង្កើតធារាសាស្ត្រជាច្រើនទៀត សម្រាប់ស្រោចស្រពលើផ្ទៃដីដាំដុះទូទាំងខេត្ត ពិសេសសម្បូរទៅដោយមច្ឆាជាតិទឹកសាបគ្រប់ប្រភេទ។

សណ្ឋានដីខេត្តចែកចេញជា ៣ តំបន់គឺ៖ (១)តំបន់វាលទំនាប៖ ជាតំបន់លិចទឹកនៅរដូវវស្សាដែលជាប្រភេទដីល្បាប់នៅតាមដងទន្លេសាបសម្បូរទៅដោយជីជាតិដែលជាកត្តាអំណោយផលយ៉ាងល្អ មានសក្តានុពល លើការដាំដុះដំណាំបន្លែ ចំការ ស្រូវប្រាំង និងផលនេសាទ ដែលតំបន់នេះមាននៅជាប់ព្រំប្រទល់ខេត្តកំពង់ធំ និងខេត្តកំពង់ចាម (២)តំបន់វាលរាប៖ មានដង់ស៊ីតេប្រជាជនរស់នៅខ្ពស់ជាងគេ ប្រជាជនភាគច្រើនបានទទួលនូវសេវាសារធារណៈខ្ពស់ជាងតំបន់នានា មានសក្តានុពលសេដ្ឋកិច្ចលើការដាំដុះស្រូវវស្សា ស្រោចស្រពដោយទឹកភ្លៀង និងប្រព័ន្ធធារាសាស្ត្រ និងសកម្មភាពរដ្ឋបាល សេដ្ឋកិច្ច សង្គមកិច្ចយ៉ាងសកម្ម។ តំបន់នេះមានទីតាំងនៅផ្នែកកណ្តាលចន្លោះផ្លូវដែក និងផ្លូវជាតិលេខ៥ (៣)តំបន់ព្រៃភ្នំ៖ ស្ថិតនៅខាងលិចផ្លូវដែកប៉ែកខាងលើជាប់ ខេត្តកំពង់ស្ពឺ និងខេត្តពោធិ៍សាត់ មានសក្តានុពលលើការដាំដុះដំណាំស្រូវ អនុផលព្រៃឈើ និងសត្វព្រៃ។ ស្រុក២ គឺស្រុកកំពង់លែង និងស្រុកជលគិរី ដែលស្ថិតនៅតំបន់វាលទំនាបរួមមាន ១៤ឃុំ ស្ថិតនៅទិសខាងជើងភាគខាងកើតនៃខេត្ត។ ឃុំភាគច្រើននៃខេត្ត ស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៥ ដែលមានភាពងាយស្រួលក្នុងការទទួលនូវសេវាសារធារណៈ សកម្មភាពទីផ្សារ និងសកម្មភាពសេដ្ឋកិច្ច សង្គមកិច្ច។

ខេត្តមានហេដ្ឋារចនាសម្ព័ន្ធផ្លូវគមនាគមន៍កាត់ខ្ចាត់ខ្ចែងគឺ៖ កំណាត់ផ្លូវជាតិលេខ៥ឆ្លងកាត់ខេត្តកំពង់ឆ្នាំង (ព្រំប្រទល់ខេត្តកំពង់ស្ពឺ ដល់ស្រុកក្រគរខេត្តពោធិ៍សាត់) មានប្រវែង ៩៣,៩គ.ម។ ផ្លូវទឹកដែលឆ្លងកាត់ខេត្តកណ្តាល កំពង់ឆ្នាំង មានប្រវែង ១១០គ.ម ពីភ្នំពេញ-កំពង់ឆ្នាំង មានប្រវែង ១០០គ.ម។ ផ្លូវដែកមានប្រវែង ៧៣គ.ម មានព្រលានយន្តហោះដែលជាសក្តានុពលដល់ការរៀបចំផ្លូវអាកាស។ ក្រៅពីនេះ យើងមានផ្លូវខេត្ត ផ្លូវលំកាត់ខ្ចាត់ខ្ចែងពីតំបន់ជនបទមកទីប្រជុំជនស្រុក ខេត្ត ដែលធានាដល់ការចរាចរទំនិញ និងសកម្មភាព សេដ្ឋកិច្ចរបស់ប្រជាជនក្នុងខេត្ត។

ទន្ទឹមនឹងនោះផងដែរខេត្តនៅមានសក្តានុពលទេសចរណ៍ធម្មជាតិ រមណីយដ្ឋានធម្មជាតិ និងកែច្នៃជាច្រើនកន្លែង វប្បធម៌ប្រវត្តិសាស្ត្រ ប្រាសាទបុរាណ និងតំបន់ជាច្រើនទៀតដែលអាចផ្តល់នូវសក្តានុពលសម្រាប់ឱ្យយើងកែច្នៃទៅជាកន្លែងទេសចរណ៍កំសាន្តដូចជា៖ រមណីយដ្ឋានភ្នំរាប់បាត្រ ភ្នំនាងកង្រី ភ្នំក្រាំងដីមាស ទួលអំពិល វត្តត្រឡែងកែង ទឹកធ្លាក់ភ្នំឱរ៉ាល់។ល។

១.២. ចំនួនប្រជាជន

យោងតាមទិន្នន័យមូលដ្ឋានឃុំ/សង្កាត់ ខេត្តកំពង់ឆ្នាំង មានប្រជាពលរដ្ឋរស់នៅចំនួន ១៣៤.៦៤៨ គ្រួសារ ប្រជាពលរដ្ឋសរុប ៥៦១.៨៩៩នាក់ ក្នុងនោះស្រី ២៩០.៧៩៤នាក់ (៥១,៨%)។ ទំហំគ្រួសារជាមធ្យម ៤,១៧នាក់ ក្នុងមួយគ្រួសារ។ មនុស្សដែលមានអាយុពី0-១៧ឆ្នាំ មានចំនួន ២១១.៤១៧នាក់ ស្មើនឹង ៣៧,៦%។ មនុស្ស ដែលមានអាយុពី១៨-៦០ឆ្នាំ មានចំនួន ២៩៤.៩២២នាក់ ស្មើនឹង ៥២,៥% និងមនុស្សដែលមានអាយុ៦១ឆ្នាំ ឡើង មានចំនួន ៥៥.៥៦០នាក់ ស្មើនឹង ៩,៩%។

ក្រាហ្វិក ១ បានបង្ហាញថា អត្រាកំណើនប្រជាជនប្រចាំឆ្នាំបានកើនឡើងពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៨ (0,២៧% ដល់ ១,៤៤%) ប៉ុន្តែអត្រាកំណើននេះ បានថយចុះក្នុងឆ្នាំ២០១៩មកនៅត្រឹម ០,៥៥%។

ក្រាហ្វិក ១៖ អត្រាកំណើនប្រជាជនប្រចាំឆ្នាំ



ប្រភព៖ទិន្នន័យមូលដ្ឋានឃុំ/សង្កាត់

យោងតាមក្រាហ្វិក២ បានបង្ហាញថា ស្ត្រីមានចំនួនច្រើនជាងបុរស នៅគ្រប់ក្រុង/ស្រុក ហើយក្នុងចំណោមក្រុង/ស្រុកទាំងនោះ ស្រុកកំពង់ត្រឡាច (បុរសចំនួន៤៨.៧៣៩នាក់ ស្ត្រីចំនួន៥២.៩២៤នាក់) និងស្រុករលាប្អៀរ (បុរសចំនួន៥៤.០២៩នាក់ និងស្ត្រីចំនួន៥៨.៦០០នាក់) មានចំនួនប្រជាជនច្រើនជាងគេ។

ក្រាហ្វិក ២៖ ចំនួនប្រជាជនបែងចែកតាមក្រុង/ស្រុកក្នុងឆ្នាំ២០១៩



ប្រភព៖ ទិន្នន័យមូលដ្ឋានឃុំ/សង្កាត់

ក្រាហ្វិក៣ បានបង្ហាញថា ស្ត្រីជាមេគ្រួសារ មានពី១០ ទៅ២០ភាគរយ ដែលចំនួននេះខ្ពស់ជាងគេនៅក្នុងស្រុកបរិបូណ៌ (២០,៧%) និងស្រុករលាប្អៀរ (១៩,៤%)។ ម៉្យាងវិញទៀត ស្រុកជលគីរីមានស្ត្រីដែលជាមេគ្រួសារទាបជាងគេ (១២,៩%)។

ក្រាហ្វិក ៣៖ ភាគរយស្ត្រី និងបុរសជាមេគ្រួសារបែងចែកតាមក្រុង/ស្រុកក្នុងឆ្នាំ២០១៩



ប្រភព៖ ទិន្នន័យមូលដ្ឋានឃុំ/សង្កាត់

១.៣. ស្ថានភាពភាពក្រីក្រ

១.៣.១. អត្រាភាពក្រីក្រនៅក្នុងខេត្ត

ក្រាហ្វិក៤ បានបង្ហាញថា អត្រាភាពនៃក្រីក្រនៅក្នុងខេត្តកំពង់ឆ្នាំង បានថយចុះគួរឱ្យកត់សម្គាល់ពី ៣២,៣% ក្នុងឆ្នាំ២០០៩ មកត្រឹម ១៨,៩% ក្នុងឆ្នាំ២០១៩។

ក្រាហ្វិក ៤៖ អត្រាភាពក្រីក្រ នៅក្នុងខេត្តកំពង់ឆ្នាំងបែងចែកតាមឆ្នាំ



ប្រភព៖ ទិន្នន័យមូលដ្ឋានឃុំ/សង្កាត់

១.៣.២. ការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅក្នុងខេត្ត

ការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រខេត្តកំពង់ឆ្នាំង បានដំណើរការ៤លើកគឺ៖ លើកទី១ ឆ្នាំ២០១០ មានគ្រួសារក្រីក្រសរុបចំនួន ៣៦,៧% (គ្រួសារក្រកម្រិត១ មានចំនួន ១៨,៤% និងគ្រួសារក្រកម្រិត២ មានចំនួន ១៨,៣%)។ លើកទី២ ឆ្នាំ២០១៣ មានគ្រួសារក្រីក្រចំនួន ២៨,៩% (គ្រួសារក្រកម្រិត១ មានចំនួន ១៣,៧% និង

គ្រួសារក្រកម្រិត២ មានចំនួន ១៥,២%) ។ លើកទី៣ ឆ្នាំ២០១៦ មានគ្រួសារក្រីក្រ ចំនួន ២៤,៨% (គ្រួសារក្រកម្រិត១ មានចំនួន ១១,០% និងគ្រួសារក្រកម្រិត២ ចំនួន ១៣,៨%) និងលើកទី៤ ឆ្នាំ២០១៩ មានគ្រួសារក្រីក្រ ចំនួន ១៩,៩% (គ្រួសារក្រកម្រិត១ មានចំនួន៨,២% និងគ្រួសារក្រកម្រិត២ ចំនួន ១១,៧%)។

យោងតាមតារាងទី១ បានបង្ហាញថា ក្នុងចំណោមក្រុង/ស្រុកទាំងអស់ អត្រាភាពក្រីក្រខ្ពស់ជាងគេ គឺនៅក្នុងស្រុកកំពង់លែង បន្ទាប់មកគឺស្រុកជលគីរី និងស្រុកទឹកផុស។ ដោយឡែក អត្រាភាពក្រីក្រទាបជាងគេមាននៅក្នុងស្រុកបរិបូណ៌។

តារាងទី១៖ គ្រួសារក្រីក្រ នៃការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រឆ្នាំ២០១៩

កូដ	ក្រុង ស្រុក	ចំនួនគ្រួសារក្នុងភូមិសម្រាប់អត្តញ្ញាណកម្មគ្រួសារក្រីក្រ	ចំនួនគ្រួសារក្រីក្រ					
			គ្រួសារក្រីក្រកម្រិត១		គ្រួសារក្រីក្រកម្រិត១		គ្រួសារក្រីក្រកម្រិត១	
			ចំនួនគ្រួសារ	ចំនួនគ្រួសារ	ចំនួនគ្រួសារ	ចំនួនគ្រួសារ	ចំនួនគ្រួសារ	ចំនួនគ្រួសារ
401	បរិបូណ៌	១៤.៤៦៨	១.០៥៥	៧,៣%	១.៣៨៨	៩,៦%	២.៤៤៣	១៦,៩%
402	ជលគីរី	៧.៩១១	៦៤៤	៨,១%	១.០៧៤	១៣,៦%	១.៧១៨	២១,៧%
403	កំពង់ឆ្នាំង	៨.៨៣១	៧៨១	៨,៨%	១.០៥៨	១២,០%	១.៨៤០	២០,៨%
404	កំពង់លែង	១២.៥១២	១.៣៣២	១០,៦%	១.៤៤៣	១១,៥%	២.៧៧៥	២២,២%
405	កំពង់ត្រឡាច	២២.៩៦៤	១.៧១៧	៧,៥%	២.២១៥	៩,៧%	៣.៩៣២	១៧,១%
406	រលាប្អៀរ	២៧.១៨០	២.២២៦	៨,២%	៣.២៣០	១១,៩%	៥.៤៥៦	២០,១%
407	សាមគ្គីមានជ័យ	២០.២៣០	១.៣៥១	៦,៧%	២.៤៨៥	១២,៣%	៣.៨៣៦	១៩,០%
408	ទឹកផុស	១៦.៧០៥	១.៣៥១	៨,១%	២.២០៤	១៣,២%	៣.៥៥៥	២១,៣%
	សរុប	**១៣០.៨១១**	**១០.៤៥៧**	**៨,២%**	**១៥.០៩៨**	**១១,៧%**	**២៥.៥៥៥**	**១៩,៩%**

ប្រភព៖ មន្ទីរផែនការ ខេត្តកំពង់ឆ្នាំង

១.៤. អភិវឌ្ឍន៍ជនបទ

តារាងទី២ បានបង្ហាញថា ភាគរយគ្រួសារដែលប្រើប្រាស់ទឹកបានឆ្លងកាត់ប្រព័ន្ធធ្វើទឹកឱ្យស្អាត មានការកើនឡើងជាលំដាប់ ពី៧២,៥% ដល់៧៧,៥% (ពីឆ្នាំ២០១៤-២០១៩) ភាគរយគ្រួសារបរិភោគទឹកស្អាត មានការកើនឡើងជារៀងរាល់ឆ្នាំផងដែរ ពី៧៥,0% ដល់៨២,៤% (ពីឆ្នាំ២០១៤-២០១៩) ហើយការប្រើប្រាស់បង្គន់អនាម័យ ក៏មានភាពល្អប្រសើរឡើងដែរ។ ម្យ៉ាងវិញទៀត គ្រួសារដែលមានបង្គន់ប្រើប្រាស់មានការកើនឡើងពី ៤0,៦% ដល់៦៧,៨% (ពីឆ្នាំ២០១៤-២០១៩) និងគ្រួសារដែលប្រើប្រាស់បង្គន់មានបច្ចេកទេសមានការកើនឡើងពី៣៣,២% ដល់៦១,៦% (ពីឆ្នាំ២០១៤-២០១៩)។

តារាងទី២៖ សូចនាករ និងចំណុចដៅនៃវិស័យអភិវឌ្ឍន៍ជនបទក្នុងឆ្នាំ២០១៩

បរិយាយ	ឯកតា	២០១៤	២០១៥	២០១៦	២០១៧	២០១៨	២០១៩
គ្រួសារប្រើប្រាស់ទឹកបានឆ្លងកាត់ពីប្រព័ន្ធធ្វើទឹកឱ្យស្អាត	%	៧២,៥	៧៣,៧	៧៤,0	៧៤,៨	៧៥,៩	៧៧,៥
គ្រួសារទទួលទានទឹកស្អាត	%	៧៥,0	៧៦,៤	៧៧,៧	៧៧,៧	៧៩,៧	៨២,៤
គ្រួសារមានបង្គន់អនាម័យប្រើប្រាស់	%	៤0,៦	៤៥,១	៤៧,៤	៥២,៤	៥៧,៣	៦៧,៨

គ្រួសារប្រើប្រាស់បង្គន់មានបច្ចេកទេស	%	៣៣,២	៣៦,៩	៤០,៤	៤៦,៤	៥០,៤	៦១,៦

ប្រភព៖ ទិន្នន័យមូលដ្ឋានឃុំ/សង្កាត់

យោងតាមក្រាហ្វិក៥ បានបង្ហាញថា នៅក្រុងកំពង់ឆ្នាំង អត្រាគ្រួសារដែលទទួលទានទឹកស្អាត ខ្ពស់ជាងគេ (៩៨,២%) ចំណែកអត្រាគ្រួសារដែលទទួលទានទឹកស្អាតមានភាគរយទាបជាងគេ គឺនៅក្នុងស្រុកកំពង់លែង (៧១,៥%)។

ក្រាហ្វិក ៥៖ ភាគរយគ្រួសារទទួលទានទឹកស្អាត បែងចែកតាមក្រុង/ស្រុកក្នុងឆ្នាំ២០១៩



ប្រភព៖ ទិន្នន័យមូលដ្ឋានឃុំ/សង្កាត់

តារាងទី៣ បានបង្ហាញថា ខេត្តបានអភិវឌ្ឍ ពង្រីកបណ្តាញអគ្គិសនីចែកចាយថាមពល ជូនប្រជាពលរដ្ឋ មានការកើនឡើងគួរឲ្យកត់សម្គាល់ពី ៣៥,៦% ដល់៧៦,៩% (ពីឆ្នាំ២០១៤-២០១៩) និងផ្ទះដែលមានទូរទស្សន៍ប្រើប្រាស់ កើនពី៦៥,៥% ដល់៨៦,៧% (ពីឆ្នាំ២០១៤-២០១៩)។

តារាងទី៣៖ ស្ថានភាពផ្ទះ និងការប្រើប្រាស់ថាមពលបំភ្លឺក្នុងឆ្នាំ២០១៩

បរិយាយ	២០១៤	២០១៥	២០១៦	២០១៧	២០១៨	២០១៩
	%	%	%	%	%	%
ផ្ទះបំភ្លឺដោយបណ្តាញអគ្គិសនី	៣៥,៦	៤៥,៨	៥១,២	៥៩,៤	៦៧,៧	៧៦,៩
ផ្ទះបំភ្លឺដោយអាគុយ	៤៧,៧	៣៨,៧	៣២,៣	២៥,៥	១៧,២	១១,៧
ផ្ទះបំភ្លឺដោយបន្ទះសូឡា	១,៥	៣,២	៥,៣	៨,១	៨,៥	៦,៩
ផ្ទះបំភ្លឺដោយឡជីវឧស្ម័ន	០,៤	០,៤	០,៤	០,៤	០,២	០,១
ផ្ទះមានទូរទស្សន៍ប្រើប្រាស់	៦៥,៥	៦៩,២	៦៩,២	៧៣,៧	៧៩,៧	៨៦,៧

ប្រភព៖ ទិន្នន័យមូលដ្ឋានឃុំ/សង្កាត់

យោងតាមក្រាហ្វិក៦ បានបង្ហាញថា ភាគរយផ្ទះប្រើប្រាស់អគ្គិសនីបែងចែកតាមក្រុង/ស្រុក ឆ្នាំ២០១៨ នៅក្រុងកំពង់ឆ្នាំងមានភាគរយខ្ពស់ជាងគេ (៩៨,៣%) ចំណែកឯអត្រាប្រើប្រាស់អគ្គីសនីទាបជាងគេ គឺនៅក្នុងស្រុកកំពង់លែង (៤២,៧%)។

ក្រាហ្វិក ៦៖ ភាគរយផ្ទះមានបណ្តាញអគ្គិសនីប្រើប្រាស់ក្នុងឆ្នាំ២០១៩



ប្រភព៖ ទិន្នន័យមូលដ្ឋានឃុំ/សង្កាត់

២. ផ្នែកសេដ្ឋកិច្ច

ខេត្តបានផ្តល់អាទិភាពក្នុងការអនុវត្តគោលនយោបាយដើម្បីបង្កើនឱកាសការងារ លើកកម្ពស់ការអប់រំ និងផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី។ បច្ចុប្បន្ននេះ មានការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងការកាត់បន្ថយគម្លាតយេនឌ័រក្នុងការទទួលបានការអប់រំ ជាពិសេសនៅកម្រិតបឋមសិក្សា អនុវិទ្យាល័យ និងការលើកកម្ពស់ការចូលរួមរបស់ក្មេងស្រីក្នុងថ្នាក់មហាវិទ្យាល័យ។ **ការលើកកម្ពស់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី**៖ រដ្ឋបាលខេត្តបានបន្តផ្តល់នូវកាលានុវត្តភាពដល់ស្ត្រីជាបន្តបន្ទាប់ និងជួយឱ្យស្ត្រីអាចបង្កើនចំណូលក្នុងគ្រួសារ តាមរយៈមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីនៅអូរសណ្តាន់ ដែលមានតួនាទីក្នុងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងសេវាអភិវឌ្ឍន៍អាជីវកម្មស្ត្រី។ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈបែងចែកជា៣គម្រោងកម្មវិធី ទី១ផ្នែកកាត់ដេរ ទី២ ផ្នែកសម្ផាងកាយ និងទី៣ ផ្នែកតម្បាញ ដែលបានបណ្តុះបណ្តាលដល់ស្ត្រីប្រមាណ ១២៥នាក់ សម្រាប់ឆ្នាំ ២០២០។ ក្នុងនោះដែរមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីដែលទាក់ទងនឹងសកម្មភាពការងារអភិវឌ្ឍសេដ្ឋកិច្ចនៅសហគមន៍មាន សកម្មភាពចំនួន ២ ដែលត្រូវអនុវត្ត ទី១ ពង្រឹងសមត្ថភាពសមាគមន៍សិប្បកម្មឬស្សី ដែលមានសមាជិកសរុប ៧៦នាក់ (ស្ត្រី ៦៤នាក់) និងទី២ ពង្រឹង និងតាមដានក្រុមការងារសន្សំប្រាក់នៅសហគមន៍ ដែលមានចំនួន ១០ក្រុម និងមានសមាជិកសរុប ២៧៦នាក់ ដែលមានស្ត្រីចំនួន ២៤២នាក់ (ដកស្រង់ចេញពី៖ ផែនការវឌ្ឍនភាពការងារនៅមជ្ឈមណ្ឌល និងសហគមន៍របស់មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីខេត្តកំពង់ឆ្នាំង)។ កម្លាំងពលកម្មជាស្ត្រី មានចំនួនច្រើននៅក្នុងផលិតកម្មនៃវិស័យកសិកម្ម និងឧស្សាហកម្មក្នុងការរកប្រាក់ចំណូលក្នុងគ្រួសារ។ ដោយសារតែការយកចិត្តទុកដាក់ការងាររបស់ស្ត្រីកាន់តែខ្លាំងឡើង គឺអាចបង្កើនប្រាក់ចំណូលសម្រាប់គ្រួសារ និងកាត់បន្ថយបន្ទុកការងារដោយផ្អែកលើតម្រូវការយេនឌ័រ ការបង្កើនផលិតភាពរបស់ស្ត្រី នាំឱ្យទទួលបានតម្លៃផលិតកម្មក្នុងគ្រួសារដើម្បីកាត់បន្ថយភាពក្រីក្រផងដែរ។ ការកើនឡើងនូវរោងចក្រកាត់ដេរ គឺបានស្រូបនូវកម្លាំងពលកម្មរបស់ស្ត្រីវ័យក្មេង ជាពិសេសស្ត្រីដែលធ្វើការនៅឆ្ងាយពីផ្ទះ។

២.១. ស្ថានភាពទូទៅរបស់វិស័យឧស្សាហកម្ម

២.១.១. ឧស្សាហកម្ម និងសិប្បកម្ម

តារាងទី៤ បានបង្ហាញថា ឧស្សាហកម្មធុនធំមានការកើនឡើងជាលំដាប់ ពី១៣ រោងចក្រ/សហគ្រាស ក្នុងឆ្នាំ២០១៤ ដល់ ២២រោងចក្រ/សហគ្រាស ក្នុងឆ្នាំ២០១៩។ នៅឆ្នាំ២០១៩ មានកម្មករនិយោជិតចំនួន ៤៤.២៤០ នាក់ (ស្រី ៣៨.៥៩៤ នាក់) ដែលភាគច្រើន ពួកគាត់ធ្វើការនៅក្នុងរោងចក្រសម្លៀកបំពាក់។

តារាងទី៤៖ រោងចក្រ/សហគ្រាសធុនធំ របស់ខេត្ត

បរិយាយ	២០១៤		២០១៥		២០១៦		២០១៧		២០១៨		២០១៩	
	រោងចក្រ	កម្មករ	រោងចក្រ	កម្មករ	រោងចក្រ	កម្មករ	រោងចក្រ	កម្មករ	រោងចក្រ	កម្មករ	រោងចក្រ	កម្មករ
រោងចក្រសម្លៀកបំពាក់	៦	១៥.៤៤៣	៨	១៥.៨២៧	៩	១៩.៦៧២	៩	២០.៩៥៩	១៣	២៤.២១៣	១២	១៨.៣០៩
រោងចក្រដេរស្បែកជើង	៣	១០.១៥៥	៣	១១.៥៩៣	៣	១៣.៤៤១	៣	១៣.១៩៨	២	១២.០៩១	៣	១៥.៨៣៨
រោងចក្រស្រាបៀ និងភេសជ្ជៈ	២	២២៨	២	២០៤	២	២២០	២	២២០	២	១៩៩	២	១៩៩
រោងចក្រផលិតកាបូប	១	៨២	១	១.៤៣៧	១	៤.៦៩៧	១	៤.៦៨៧	២	៨.១០២	២	៩.៥៨៤
រោងចក្រកិនស្រូវធុនធំ	០	០	២	១៨៧	២	១៨៧	២	១៧៨	២	២០៧	២	២១៥
សហគ្រាសផលិតឱសថ	១	៩៥	១	៩០	១	៩៥	១	៩៥	១	៩៥	១	៩៥
សរុប	**១៣**	**២៦.០០៣**	**១៧**	**២៩.៣៣៨**	**១៨**	**៣៨.៣២១**	**១៨**	**៣៩.៣៣៧**	**២២**	**៤៤.៩០៧**	**២២**	**៤៤.២៤០**

ប្រភព៖ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ខេត្តមានសិប្បកម្មខ្នាតមធ្យម តូច និងសិប្បកម្មជាច្រើនទៀតគឺ៖ រោងចក្រផលិតទឹកកកដើម ទឹកកកអនាម័យ រោងចក្រផលិតទឹកស្អាតរបស់អង្គភាពរដ្ឋាករទឹកខេត្ត និងក្រុមហ៊ុនអានកូ សិប្បកម្មកាត់ដេរ សិប្បកម្មផលិតទឹកបរិសុទ្ធ សិប្បកម្មកិនស្រូវ សិប្បកម្មផលិតឥដ្ឋ សិប្បកម្មក្រឡឹង និងសិប្បកម្ម ផ្សេងៗទៀត។

តារាងទី៥៖ តារាងសិប្បកម្មនៅក្នុងខេត្ត

បរិយាយ	២០១៤	២០១៥	២០១៦	២០១៧	២០១៨	២០១៩
ម៉ាស៊ីនកិនស្រូវខ្នាតមធ្យម ឬធំ	១.៧៧១	២.០៧១	១.៩០៤	២.០១៣	១.៨៨៨	១.៤៣០
សិប្បកម្មឡឥដ្ឋ	៣១	៣៤	៣៥	៣០	២៦	២៦
សិប្បកម្មត្បាញរៃ	៩	៥	៤	៥	៧	៧
សិប្បកម្មផលិតពីផ្តៅ ឫស្សី រពាក់	៤២៦	២៤០	២៤៤	២៦៥	២២០	២២០
សិប្បកម្មចម្លាក់ពីស្ពាន់ ថ្ម ស្បែក	៧	៥	៧	៧	១៣	១៣
សិប្បកម្មផលិតពីដែកអាលុយមីញ៉ូម	៥១	២៧	២៦	៣៧	៤១	៤១
សិប្បកម្មផលិតពីជ័រ	០	១	៤	៤	៤	៥
សិប្បកម្មផលិតទឹកបរិសុទ្ធ	១៧	៣១	៣៣	៤២	៥៣	៥៦

ប្រភព៖ មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

២.១.២. ៩៖

ការងារអាជីវកម្ម៖ មានសកម្មភាពអាជីវកម្មវាយថ្មមានអាជ្ញាប័ណ្ណដំណើរការសរុបចំនួន ១៣ មូលដ្ឋាន ក្នុងនោះមាន ៧ មូលដ្ឋាន ស្ថិតនៅក្នុងឃុំពង្រ និងឃុំស្រែថ្មី ស្រុករលាប្ជៀរ និង ១មូលដ្ឋានទៀតស្ថិត នៅក្នុងឃុំព្រៃគ្រី ស្រុកជលគីរី ៣ មូលដ្ឋាន នៅស្រុកទឹកផុស និង ២ មូលដ្ឋាន នៅស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង។

២.១.៣. ពាណិជ្ជកម្ម

ខេត្តមានផ្សារចំនួន ១៧កន្លែង ក្នុងនោះផ្សារធំមានចំនួន ២កន្លែង ផ្សារធុនកណ្តាលនៅតាមស្រុកមានចំនួន ៥ កន្លែង ផ្សារធុនតូចមាននៅតាមបណ្តាឃុំមានចំនួន ១០ កន្លែង។ មូលដ្ឋានអាជីវកម្មមានចំនួន ២.៣១៥ តូបអាជីវកម្មដែលក្នុងនោះប្រភេទពាណិជ្ជកម្ម ១.៦២៧ តូបអាជីវកម្ម ប្រភេទសេវាកម្ម ៤១០ តូបអាជីវកម្ម សិប្បកម្មផលិត ៩៤ តូបអាជីវកម្ម ប្រេងនិងឧស្ម័នឆេះ ១០៦ តូបអាជីវកម្ម។ សកម្មភាពទីផ្សារនៃការដោះដូរទំនិញដូចជាសម្លៀកបំពាក់ ក្រុមហ៊ុនឯកជនសំណង់ ការនាំទំនិញផលិតផលកសិកម្មនិងកសិ-ឧស្សាហកម្ម ផលិតផលត្រីទឹកសាប បសុសត្ត និងសត្វស្លាបនានាយកទៅលក់នៅលើទីផ្សារក្នុងស្រុក និងក្រៅស្រុក។

២.២. ចំនួនប្រជាជន និងមុខរបរ

យោងតាមតារាងទី៦ បានបង្ហាញថា អត្រាប្រជាជនដែលមានអាយុពី១៨-៦០ឆ្នាំ មានមុខរបរចម្បងៗ ក្នុងវិស័យទាំងបី (វិស័យកសិកម្ម វិស័យឧស្សាហកម្ម និងសិប្បកម្ម និងវិស័យសេវាកម្ម) ក្នុងចំណោមវិស័យទាំងនោះ អត្រាប្រជាជនដែលបម្រើការក្នុងវិស័យកសិកម្មមានការថយចុះជាលំដាប់ ពី៧៦,១% ក្នុងឆ្នាំ២០១៥ មកត្រឹម ៦៨,៦% ក្នុងឆ្នាំ២០១៩។

តារាងទី៦៖ ស្ថានភាពមុខរបរចម្បងរបស់ប្រជាជន

បរិយាយ	២០១៥	២០១៦	២០១៧	២០១៨	២០១៩
ចំនួនប្រជាជនសរុបដែលធ្វើការងារក្នុងវិស័យកសិកម្មជាមុខរបរចម្បង	១៩៩.២២៨	១៩៣.៦៣១	១៩៧.១៩៣	១៩៣.៩១៧	១៨៩.១៥៣
% ប្រជាជនដែលធ្វើការងារក្នុងវិស័យកសិកម្ម	៧៦,១	៧៣,៧	៧២,២	៧០,៥	៦៨,៦
% ស្ត្រីដែលធ្វើការងារក្នុងវិស័យកសិកម្ម (មុខរបរចម្បង)	៣៧,៨	៣៦,៧	៣៦,១	៣៤,៦	៣៣,៤
ចំនួនប្រជាជនសរុបដែលធ្វើការងារក្នុងវិស័យឧស្សាកម្ម និងសិប្បកម្ម ជាមុខរបរចម្បង	១.៥៩៤	១.៦២២	១.៧១៨	១.៧៣៤	១.៨២១
% ប្រជាជនដែលធ្វើការងារក្នុងវិស័យឧស្សាហកម្ម និងសិប្បកម្ម	០,៦	០,៦	០,៦	០,៦	០,៧
% ស្ត្រីដែលធ្វើការងារក្នុងវិស័យឧស្សាហកម្ម និងសិប្បកម្ម	០,២	០,២	០,២	០,២	០,៣
ចំនួនប្រជាជនសរុបដែលធ្វើការក្នុងផ្នែកសេវាកម្មជាមុខរបរចម្បង	៦១.១៤៤	៦៧.៥១៥	៧៤.៤៩៨	៧៩.៤៦១	៨៤.៧២២
% ប្រជាជនដែលធ្វើការក្នុងផ្នែកសេវាកម្ម	២៣,៣	២៥,៧	២៧,២	២៨,៩	៣០,៧
% ស្ត្រីដែលធ្វើការក្នុងផ្នែកសេវាកម្ម	១២,៤	១៤,៣	១៥,២	១៦,១	១៧,១

ប្រភព៖ ទិន្នន័យមូលដ្ឋានឃុំ/សង្កាត់

យោងតាមក្រាហ្វិក៧ បានបង្ហាញថា មុខរបរកសិកម្មនៅតែជាមុខរបរចម្បង ដែលមានប្រជាជនចូលរួមច្រើនជាងគេ (បុរស៣៥,២% និងស្ត្រី៣៣,៤%) ក្នុងឆ្នាំ២០១៩។

ក្រាហ្វិក ៧៖ ភាគរយប្រជាជន ដែលមានអាយុពី១៨-៦០ឆ្នាំ បែងចែកតាមមុខរបរចម្បង និងតាមភេទក្នុងឆ្នាំ ២០១៩



ប្រភព៖ ទិន្នន័យមូលដ្ឋានឃុំ/សង្កាត់

ក្រាហ្វិក៨ បានបង្ហាញថា ប្រជាជនដែលមានអាយុចាប់ពី១៨ឆ្នាំឡើង ធ្វើការងារក្នុងវិស័យកសិកម្ម(មុខរបរចម្បង) នៅក្នុងស្រុករលាប្អៀរ មានប្រជាជនចូលរួមច្រើនជាងគេ (បុរសមាន១៩.២២៥នាក់ និងស្ត្រីមាន ១៩.៧៤៧នាក់)។ ក្នុងចំណោមក្រុង/ស្រុកទាំងអស់ ស្ត្រីចូលរួមក្នុងវិស័យកសិកម្មមានចំនួនច្រើនជាងបុរស នៅក្នុងស្រុករលាប្អៀរ ទឹកផុស កំពង់លែង និងស្រុកបរិបូណ៌។

ក្រាហ្វិក ៨៖ ប្រជាជនដែលមានអាយុពី១៨ឆ្នាំឡើង ធ្វើការងារក្នុងវិស័យកសិកម្ម (មុខរបរចម្បង) បែងចែកតាមភេទ និងក្រុង/ស្រុកក្នុងឆ្នាំ២០១៩



ប្រភព៖ ទិន្នន័យមូលដ្ឋានឃុំ/សង្កាត់

យោងតាមក្រាហ្វិក៩ បានបង្ហាញថា នៅគ្រប់ក្រុង/ស្រុក ចំនួនបុរស និងស្ត្រីបម្រើការងាររលើវិស័យឧស្សាហកម្ម និងសិប្បកម្ម ភាគច្រើនមាននៅក្នុងស្រុករលាប្អៀរ ស្រុកកំពង់ត្រឡាច និងក្រុងកំពង់ឆ្នាំង។ ដោយឡែក ក្នុងស្រុករលាប្អៀរ មានចំនួនស្ត្រីដែលធ្វើការក្នុងវិស័យឧស្សាហកម្ម និងសិប្បកម្មច្រើនជាងគេ។

ក្រាហ្វិក ៩៖ ប្រជាជនដែលមានអាយុពី១៨ឆ្នាំឡើង ធ្វើការក្នុងវិស័យឧស្សាហកម្ម និងសិប្បកម្ម (មុខរបរចម្បង) បែងចែកតាមភេទ និងក្រុង/ស្រុកក្នុងឆ្នាំ២០១៩



ប្រភព៖ ទិន្នន័យមូលដ្ឋានឃុំ/សង្កាត់

យោងតាមក្រាហ្វិក១០ បានបង្ហាញថា ប្រជាពលរដ្ឋដែលបម្រើការងាររលើវិស័យសេវាកម្មមាននៅគ្រប់ក្រុង/ស្រុកទាំងអស់ ប៉ុន្តែក្នុងចំណោមក្រុង/ស្រុកទាំងនោះ ស្រុកកំពង់ត្រឡាច និងស្រុកសាមគ្គីមានជ័យ មានស្ត្រីដែលបម្រើការងារផ្នែកនេះខ្ពស់ជាងគេ ពីព្រោះស្រុកទាំងពីរនេះស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៥ និងមានតំបន់ជាច្រើនសម្រាប់ធ្វើអាជីវកម្ម។

ក្រាហ្វិក ១០៖ ប្រជាជនមានអាយុ១៨ឆ្នាំឡើង ធ្វើការក្នុងផ្នែកសេវាកម្ម (មុខរបរចម្បង) បែងចែកតាមភេទ និងក្រុង/ស្រុក ក្នុងឆ្នាំ២០១៩



ប្រភព៖ ទិន្នន័យមូលដ្ឋានឃុំ/សង្កាត់

យោងតាមក្រាហ្វិក១១ បានបង្ហាញថា ប្រាក់ខែអប្បបរមា របស់កម្មករនិយោជិត មានការកើនឡើងជាលំដាប់ ពី១០០ដុល្លារ ក្នុងឆ្នាំ២០០៤ ដល់១៩០ដុល្លារ ក្នុងឆ្នាំ២០២០។

ក្រាហ្វិក ១១៖ ប្រាក់ខែអប្បបរមារបស់កម្មករនិយោជិត



ប្រភព៖ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

២.៣. ចំណាកស្រុក

យោងតាមតារាងទី៧ បានបង្ហាញថា ភាគរយនៃអ្នកធ្វើចំណាកស្រុកនៅក្នុងប្រទេស មានប្រមាណ ១០% និងក្រៅប្រទេសប្រមាណ ៦% រវាងបុរស និងស្ត្រីពីឆ្នាំ២០១៧ ដល់ឆ្នាំ២០១៩។ ម៉្យាងវិញទៀត ភាគរយបុរសដែលបានធ្វើចំណាកស្រុកក្នុង និងក្រៅប្រទេស ខ្ពស់ជាងស្ត្រី។

តារាងទី៧៖ អត្រាចំណាកស្រុក

បរិយាយ	២០១៧	២០១៨	២០១៩
សរុបចំនួនបុរសដែលមានអាយុ១៨ឆ្នាំឡើង	១៦១.៧៨៥	១៦៤.៦០៦	១៦៥.៣៥៦
សរុបចំនួនស្ត្រីដែលមានអាយុ១៨ឆ្នាំឡើង	១៨១.៨២០	១៨៣.៨៥២	១៨៥.១២៦
% បុរសដែលធ្វើចំណាកស្រុកក្នុងប្រទេស	៨,៥	៨,១	៩,២
% ស្ត្រីដែលធ្វើចំណាកស្រុកក្នុងប្រទេស	៧,៧	៧,៥	៨,៣
% បុរសដែលធ្វើចំណាកស្រុកក្រៅប្រទេស	៥,៤	៥,២	៥,០
% ស្ត្រីដែលធ្វើចំណាកស្រុកក្រៅប្រទេស	២,៥	២,៥	២,៥

ប្រភព៖ ទិន្នន័យមូលដ្ឋានឃុំ/សង្កាត់

យោងតាមក្រាហ្វិកខាងក្រោម បានបង្ហាញថា ក្នុងចំណោមក្រុង/ស្រុកទាំងអស់ ស្រុករលាប្អៀរមានអ្នកចំណាកស្រុកក្នុងប្រទេសច្រើនជាងគេ ទាំងបុរស និងស្ត្រី រីឯក្រុងកំពង់ឆ្នាំងមានអ្នកចំណាកស្រុកក្នុងប្រទេសទាបជាងគេ។ ម្យ៉ាងវិញទៀត ស្រុករលាប្អៀរ ស្រុកជលគីរី ស្រុកកំពង់លែង និងស្រុកទឹកផុស មានស្ត្រីធ្វើចំណាកស្រុកខ្ពស់ជាងបុរស។

ក្រាហ្វិក ១២៖ ចំនួនស្ត្រី និងបុរសអាយុ១៨ឆ្នាំឡើង ដែលធ្វើចំណាកស្រុកក្នុងប្រទេស ក្នុងឆ្នាំ២០១៩



ប្រភព៖ ទិន្នន័យមូលដ្ឋានឃុំ/សង្កាត់

យោងតាមក្រាហ្វិកខាងក្រោម បានបង្ហាញថា ក្នុងចំណោមក្រុង/ស្រុកទាំងអស់ ស្រុករលាប្អៀរ និងស្រុកទឹកផុស មានចំនួនអ្នកចំណាកស្រុកទៅក្រៅប្រទេសច្រើនជាងគេ ហើយអ្នកធ្វើចំណាកស្រុកទាំងនោះ ភាគច្រើនជាបុរស។ លើសពីនោះទៅទៀត ស្ត្រីដែលបានធ្វើចំណាកស្រុកច្រើនជាងគេ គឺមាននៅក្នុងស្រុកទឹកផុស ស្រុករលាប្អៀរ ស្រុកកំពង់លែង និងស្រុកបរិបូណ៌។

ក្រាហ្វិក ១៣៖ ចំនួនស្ត្រី និងបុរស អាយុ១៨ឆ្នាំឡើង ដែលធ្វើចំណាកស្រុកទៅក្រៅប្រទេស ក្នុងឆ្នាំ២០១៩



ប្រភព៖ ទិន្នន័យមូលដ្ឋានឃុំ/សង្កាត់

៣. ផ្នែកអប់រំ

៣.១. កម្រិតមត្តេយ្យសិក្សា

តារាងទី៨ បានបង្ហាញអំពី ចំនួនសាលា ចំនួនគ្រូ និងចំនួនសិស្សនៅថ្នាក់មត្តេយ្យសិក្សា (មត្តេយ្យសិក្សារដ្ឋ មត្តេយ្យសិក្សាសហគមន៍ មត្តេយ្យសិក្សាឯកជន និងអប់រំកុមារតូចតាមផ្ទះ) ហើយចំនួនសិស្សមានការកើនឡើង នៅមត្តេយ្យសិក្សារដ្ឋ និងមត្តេយ្យសិក្សាសហគមន៍ ចាប់ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៩ ។

តារាងទី៨៖ ផ្នែកមត្តេយ្យសិក្សា

សូចនាករ	ឯកតា	២០១៤	២០១៥	២០១៦	២០១៧	២០១៨	២០១៩
១.មត្តេយ្យសិក្សារដ្ឋ							
សាលា	សាលា	៩៤	៩៩	១០៥	១១០	១១២	១១៣
គ្រូ	នាក់	១៩៥	១៩៧	២៣២	២២៦	២៣៦	២៣៥
គ្រូស្រី	នាក់	១៨៩	១៩១	២២៥	២២០	២៣១	២២៧
សិស្សសរុប	នាក់	៥.៤៣៥	៥.៧៦៧	៦.១៦០	៦.៥៣៦	៦.៩១៤	៧.១៧១
សិស្សស្រី	នាក់	២.៧០៧	២.៩៩០	៣.០៦៩	៣.២៧៣	៣.៤៥២	៣.៥៤៥
សិស្សប្រុស	នាក់	២.៧២៨	២.៧៧៧	៣.០៩១	៣.២៦៣	៣.៤៦២	៣.៦២៦
២-មត្តេយ្យសិក្សាសហគមន៍							
សាលា	សាលា	១០៦	១៣៦	១៣៤	១៥៩	១៧៨	២០៤
គ្រូ	នាក់	១០៧	១៣៦	១៣៤	១៦៣	១៨៩	២១៧
គ្រូស្រី	នាក់	១០៦	១២៨	១២៦	១៥៤	១៧៨	២០៤
សិស្សសរុប	នាក់	២.៧៥៣	៣.៥៨០	៣.៤៦៦	៤.២៣៥	៤.៩៦៧	៥.៥៧០
សិស្សស្រី	នាក់	១.៤៧០	១.៨១៧	១.៧១០	២.១៩០	២.៥៩០	២.៨៦៦
សិស្សប្រុស	នាក់	១.២៨៣	១.៧៦៣	១.៧៥៦	២.០៤៥	២.៣៧៧	២.៧០៤
៣-មត្តេយ្យសិក្សាឯកជន							
សាលា	សាលា	៦	៤	៥	៩	១១	១០
គ្រូ	នាក់	៣៧	៣០	៣៦	៧៨	៩៩	៧៨
គ្រូស្រី	នាក់	៣៤	២៦	៣៣	៦៨	៨៦	៧២
សិស្ស	នាក់	៨២៧	៦៨៦	៧៦៤	១.៣៤៣	១.៥៣២	១.៣៣៥
សិស្សស្រី	នាក់	៣៧៧	៣១០	៣៧៨	៦៨៣	៧៤១	៦២៨
សិស្សប្រុស	នាក់	៤៥០	៣៣៦	៣៨៦	៦៦០	៧៩១	៧០៧
៤-ការអប់រំកុមារតូចតាមផ្ទះ							
ភូមិ	ភូមិ	២១៩	២៣២	២០៩	២១៩	២០៣	១៥៩
ក្រុមម៉ែៗ	ក្រុម	១.៣៣៩	១.៤១៤	១.០១៩	១.០១៧	១.១៤៣	១៣៤
ម៉ែៗកុមារ	នាក់	៨.០៩១	៧.២៦២	៨.៨៧១	៥.៧៨៧	៦.៦៤៣	៤.៣១០
កុមារសរុប	នាក់	៧.៣២៩	៧.៨៥៨	៧.០១៧	៧.៤៣៦	៩.៥៥៥	៧.១៧៨
សិស្សស្រី	នាក់	៣.៧១៣	៤.០១៤	៣.៥៦០	៣.៧០៩	៤.៨០៣	៣.៦០៨
សិស្សប្រុស	នាក់	៣.៦១៦	៣.៨៤៤	៣.៤៥៧	៣.៧២៩	៤.៧៥២	៣.៥៧០

